# ករណីសិក្សានៅតុលាការកូនកាត់[1]

ដ៥ មិនា ២០០៦

តុលាការពិសេសសៀរ៉ាឡេអូន ត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលសៀរ៉ាឡេអូន និង អង្គការសហប្រជាជាតិកាលពីខែមករា ឆ្នាំ២០០២ ។ ករណីសិក្សានេះស្វែងរកការផ្តល់ព័ត៌មានជាមូលដ្ឋាន និងការវិភាគគោលនយោបាយស្តីពីតុលាការ ។ វាជាផ្នែកមួយនៃករណីសិក្សាច្រើនស៊េរីដែលមានគោលបំណងផ្តល់ព័ត៌មាន និង វិភាគគោលនយោបាយ និងបញ្ហាអនុវត្តជាក់ស្តែងនានាដែលតុលាការនេះកំពង់តែប្រឈមមុខ បញ្ហាទាំងនេះរួមមាន:

- ប្រវត្តិសង្ខេបនៃជម្លោះ និង ចរិតលក្ខណៈនៃអំពើព្រៃផ្សៃនៅសៀរ៉ាឡេអូន
- ព័ត៌មានសាវតាស្តីពីការបង្កើតតុលាការពិសេស
- ក្របខណ្ឌច្បាប់ និង យុត្តិសាស្ត្ររបស់តុលាការពិសេស
- ការពិពណ៌នាអង្គជំនុំជម្រះ ការិយាល័យព្រះរាជអាជ្ញា និង ការិយាល័យរដ្ឋបាល
- ផ្នែកការពារក្តី និង បញ្ហាទាក់ទងទៅនឹងយុត្តិធម៌
- អំណាចចោទប្រកាន់
- បញ្ហាទាក់ទងទៅនឹងប្រសិទ្ធិភាព និងថវិកា
- កិច្ចសហប្រតិបត្តិការរបស់រដ្ឋ
- កម្មវិធីផ្សព្វផ្សាយ និងទស្សនរបស់ពលរដ្ឋទៅលើតុលាការពិសេស
- តុលាការពិសេស និង គណៈកម្មាធិការស្វែងរកការពិតនិងការផ្សះផ្សារជាតិ

---

[1] ករណីសិក្សានេះតាក់តែងឡើងដោយ Tom Perrielo និង Maieke Wierda មន្ត្រីជាន់ខ្ពស់នៅមជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល (ICTJ) ។ Tom Perrielo បំរើការងារនៅតុលាការពិសេសចាប់តាំងពីថ្ងៃបង្កើតរហូតដល់ខែសីហា ឆ្នាំ២០០៣ ហើយ Maieke Wierda ជាឃ្លាំមើលរបស់ ICTJ បានឃ្លាំមើលការវិវត្តិរបស់តុលាការពិសេសជាជិតដល់ចាប់តាំងពីឆ្នាំ២០០១មកម្លេះ និងជាអ្នកនិពន្ធនៃរបាយការណ៍ជាច្រើនទាក់ទងទៅនឹងតុលាការពិសេស ។ ទស្សនដែលបង្ហាញនៅលើឯកសារ ជាទស្សនរបស់អ្នកនិពន្ធ មិនមែនជាទស្សនផ្ទាល់របស់ ICTJ ទេ ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ Caitlin Reiger, Aumi Kusafuka, Annie Bird និង អ្នកផ្សេងទៀតនៅ ICTJ និង តុលាការពិសេសចំពោះការជួយគាំទ្ររបស់ពួកគេចំពោះការធ្វើបច្ចុប្បន្នភាពលើរបាយការណ៍នេះ ។

គោលបំណងនៃករណីសិក្សានេះ គឺដើម្បីផ្តល់ព័ត៌មានជាមូលដ្ឋានដែលព័ត៌មានមួយចំនួននៅតែមិនអាចរកបាននៅឡើយ ដើម្បីធ្វើជាមគ្គុទេសក៏ដល់អ្នកធ្វើគោលនយោបាយ និងដៃគូរអភិវឌ្ឍន៏នានាដើម្បីបង្កើត និងអនុវត្តន៏យន្តការស្រដៀងគ្នា ។ ករណីសក្សាស្រដៀងគ្នានេះ ត្រូវបានបង្កើតឡើងនៅ**កូសូវ៉ូ** និង **Timor-Leste** ។

*សង្ខេបសេចក្តីសន្និដ្ឋាន*

ខណៈតុលាការពិសេសត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបនឹងសំណើរបស់រដ្ឋាភិបាល ភ្លាមៗនោះតុលាការពិសេសនេះបានក្លាយជាម៉ូដែលសម្រាប់ជម្រើសមួយចំពោះតុលាការបណ្តោះអាសន្នបង្កើតដោយអង្គការសហប្រជាជាតិ[2] ។ តុលាការពិសេសនេះត្រូវបានគេយល់ថាអនុវត្តបានល្អប្រសើរចំពោះស័ព្ទដែលមានន័យចង្អៀត "អ្នកដែលការទទួលខុសត្រូវខ្ពស់បំផុត" ដែលផ្ទុយទៅវិញវានឹងអនុញ្ញាតឲ្យមានការដាក់កម្រិតផ្នែកប្រសិទ្ធិភាពនៅពេលវាយតំលៃនូវស័ព្ទទាំងនោះ តុលាការពិសេសកំពុងតែជោគជ័យក្នុងដំណើរស្វែងរកយុត្តិធម៏សម្រាប់ឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតនៅសៀរ៉ាឡេអូន ។ មានអតីតអ្នកដឹកនាំប្រទេសសៀរ៉ាឡេអូនមួយចំនួនកំពង់តែប្រឈមមុខនឹងការកាត់ទោស ។

ប៉ុន្តែបញ្ហាថវិកា និងប្រសិទ្ធិភាព បានគ្របសង្កត់នៅឯអង្គការសហប្រជាជាតិ និងគណៈកម្មាធិការគ្រប់គ្រងដែលជាយន្តការត្រួតពិនិត្យរបស់តុលាការពិសេស ហើយស្របពេលជាមួយគ្នានេះ នៅមានបញ្ហាសំខាន់ៗមួយចំនួនមិនត្រូវយកចិត្តទុកដាក់ ។ ឧទាហរណ៏ ការដែលតុលាការពិសេសដំណើរការសវនាការនៅក្នុងប្រទេសបែបបនេះ បានផ្តល់នូវអត្ថប្រយោជន៏ រួមទាំងលទ្ធភាពអនុវត្តសកម្មភាពផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ប្រជាជនគោលដៅនៅមូលដ្ឋាន ។តុលាការបានធ្វើឲ្យប្រជាជនសៀរ៉ាឡេអូនយ៉ាងច្រើន ដែលពួកគេភាគច្រើនមិនមានតួនាទីក្នុងមុខងារផ្លូវការ អនុវត្តនីតិរដ្ឋនៅសៀរ៉ាឡេអូន ។

ទោះជាបែបនេះក្តី នៅមានបញ្ហាប្រឈមជាច្រើនទៀតៈ

- *ផលប៉ះពាល់:* ទស្សនក្នុងស្រុក និងអន្តរជាតិអំពីផលប៉ះពាល់របស់តុលាការមិនដូចគ្នាទេ ហើយមានករណីខ្លះមានភាពតានតឹង ។ ទោះបីជាតុលាការពិសេសទទួលបានការគាំទ្រនៅក្នុងប្រទេសសៀរ៉ាឡេអូន ក៏មានការយល់ឃើញនៅក្នុងប្រទេសថាអាណត្តិរបស់តុលាការនេះមានលក្ខណៈចង្អៀត មួយផ្នែកដោយសារមនុស្សតែ ១១នាក់ត្រូវបានចោទប្រកាន់ ហើយដោយសារតែជនជាប់ចោទបួននាក់

[2] ទាំងនេះរួមបញ្ចូលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និង រ៉ូវ៉ាន់ដា ដែលហៅកាត់ថា (ICTY និង ICTR) ។

ដែលមានឋានៈខ្ពស់មិនអាចប្រឈមមុខនឹងសវនាការ(ជនជាប់ចោទពីរនាក់បានស្លាប់ ហើយជនជាប់ចោទពីរនាក់ផ្សេងទៀត រួមទាំង Charles Taylor ផងដែរ ចាប់មិនទាន់បាននៅឡើយ) ។តុលាការពិសេសមានលទ្ធភាពឆ្លើយតបទៅនឹងទស្សនទាំងនេះ តាមរយៈដំណើរការកម្មវិធីផ្សព្វផ្សាយ ប៉ុន្តែការព្រួយបារម្ភទាំងនេះមិនទាន់សាបរលាបពីអារម្មណ៍របស់ប្រជាជាតិទេ។នៅលើឆាកអន្តរជាតិកេរ្តិ៍ឈ្មោះរបស់តុលាការអាស្រ័យលើសមត្ថភាពរបស់ខ្លួនក្នុងការបំពេញបេសកម្មដ៏សំខាន់មួយនេះ ដោយយកចិត្តទុកដាក់លើប្រសិទ្ធិភាព ។អាណត្តិដ៏ចង្អៀក ត្រូវបានស្គាល់ថាជាម៉ូដែលថ្មីហើយតុលាការឧក្រិដ្ឋកម្មអន្តរជាតិក៏អនុវត្តតាមម៉ូដែលនេះដែរ ប៉ុន្តែបញ្ហាប្រឈមដ៏សំខាន់បំផុតចំពោះកិត្តិនាមរបស់ខ្លួន គឺការបន្តអវត្តមាននៃជនជាប់ចោទដ៏សំខាន់បំផុត គឺអតីតប្រធានាធិបតីប្រទេស**លីបេរី** Charles Taylor ។

- *និត្យានុកូលភាព:* នីត្យានុកូលភាពរបស់តុលាការពិសេសនៅកម្រិតជាតិ ត្រូវទទួលរងនូវការប៉ះពាល់មួយផ្នែកដោយសារតែការយល់ឃើញថា តុលាការនេះមិនមែនជាតុលាការអន្តរជាតិដែលបានទទួលតាមរយៈយុត្តិសាស្ត្រ និងបឋកថារបស់ខ្លួន ។ ពុំមានជនជាតិសៀរ៉ាឡេអូនណាម្នាក់កាន់កាប់តំណែងជាន់ខ្ពស់នៅតុលាការពិសេសឡើយ ។ សូមបញ្ជាក់ថា នេះគឺជាជម្រើសរបស់រដ្ឋាភិបាលដែលបានតែងតាំងតំណែងជាច្រើនឱ្យបរទេស ដែលជនជាតិសៀរ៉ាឡេអូនសាកសមនឹងទទួលតំណែងទាំងនោះ ។ បញ្ហានេះបង្កឱ្យមានភាពគ្រោះថ្នាក់បង្កើតនូវ "Spaceship Phenomenon" ឧទាហរណ៍ តុលាការត្រូវបានគេឃើញថាគ្រាន់តែជាញាណវិឆ្នតា មិនសមហេតុសមផល ហើយមានឥទ្ធិពលតិចតួចដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនតែប៉ុណ្ណោះ ។ ឱកាសដើម្បីទទួលបាននីត្យានុភាព ត្រូវបានដាក់កម្រិតដោយសារតែភាពដាច់ឆ្ងាយពីតុលាការរបស់អ្នកប្រកបវិជ្ជាជីវៈច្បាប់ ។ កត្តាទាំងអស់នេះបានធ្វើឱ្យប៉ះពាល់ដល់ការស្តារឡើងវិញនូវនីតិរដ្ឋសម្រាប់រយៈពេលវែង និងការបង្កើតការពិតនៅក្នុងយន្តការតុលាការរបស់ប្រទេសសៀរ៉ាឡេអូន ។ប៉ុន្តែ "ការបង្ហាញនូវអនុភាព"របស់តុលាការនៅតែអាចមានផលប៉ះពាល់ដោយប្រយោលដល់ចំណេះដឹងសាធារណៈជន និងការទាមទារនូវការទទួលខុសត្រូវ នីត្យានុកូនភាពរបស់តុលាការពិសេសនៅលើឆាកអន្តរជាតិបានទទួលរងនូវការប៉ះពាល់ដោយកត្តាដែលថាតុលាការនេះមិនអនុវត្តន៏ការបែងចែកទៅតាមទីតាំងភូមិសាស្ត្ររបស់អង្គការសហប្រជជាតិ ដែលត្រូវបានត្រួតត្រាដោយប្រព័ន្ធច្បាប់កុំម៉ង់ឡូ ។ មានការចោទប្រកាន់ថាសហរដ្ឋអាមេរិកត្រួតត្រានៅការិយាល័យព្រះរាជអាជ្ញា ប៉ុន្តែវត្តមានរបស់ពួកគេបានបាត់រសាត់ទៅវិញជាបណ្តើរៗ ។
- *យុត្តិធម៌:* មេធាវីការពារក្តីនៅតុលាការពិសេសទទួលបានការគាំទ្រផ្នែកស្ថាប័នក្នុងកំរិតខ្ពស់ជាងនៅតុលាការផ្សេងៗទៀត (រួមមាន ICTY និង ICTR ផងដែរ) ។ ក៏ប៉ុន្តែ មានបញ្ហាមួយចំនួននៅបន្តការពិភាក្សានៅឡើយ ក្នុងនោះរួមមានកំរិតធនធានដែលត្រូវបែងចែកទៅឱ្យផ្នែកការពារ និងការធានា

គុណភាពការពារក្តី និង សមត្ថភាពគ្រប់គ្រាន់ ។ ទោះបីជាមានការពិភាក្សាបែបនេះក្តី ការជំនុំជម្រះក្តីនៅតុលាការពិសេស ត្រូវបានចាត់ទុកថាបានឆ្លើយតបនឹងបទដ្ឋានអន្តរជាតិ ។ ដូចគ្នានឹងលក្ខខណ្ឌឃុំខ្លួនដែរ ទោះបីប្រជាជនយល់ឃើញថាជនជាប់ចោទមានកំរិតជីវភាពរស់នៅខ្ពស់ជាប្រជាជនជាច្រើននៅសៀរ៉ាឡេអូន ទៅទៀត ។

- *ប្រសិទ្ធិភាពទូទៅ:* មកដល់ពេលបច្ចុប្បន្ននេះ តុលាការពិសេសទទួលបានជោគជ័យយ៉ាងច្រើននៅក្នុងបញ្ហាប្រសិទ្ធិភាពនេះ ។ សេចក្តីសម្រេចដើម្បីបង្រួមអាណត្តិរបស់តុលាការ បានបង្កឲ្យមានផលប៉ះពាល់យ៉ាងដល់ការចំណាយ និងពេលវេលាដែលតម្រូវដើម្បីប្រតិបត្តិការតុលាការ ។ ដីកាការចោទប្រកាន់ត្រូវបានចេញប្រាំបួន(៩)ខែរួចមកហើយ តែសវនាមានសន្ទុះទៅមុខដោយយឺតៗ ។ ប៉ុន្តែម៉ូដែលរបស់តុលាការពិសេសបានបង្ហាញនូវមធ្យោបាយនៃដំណើរការកាត់សេចក្តីដោយចំណាយទាបពិតមែនតែឆ្លើយតបនឹងបទដ្ឋានអន្តរជាតិ ។ តុលាការពិសេសទទួលបានអត្ថប្រយោជន៏ដោយសារតែជហរឯករាជ្យម្ចាស់ការ “stand-alone” ដំណើរការដោយគ្មានឧបសគ្គជាមួយប្រព័ន្ធច្បាប់ជាតិ ។ ប៉ុន្តែមានការរិះគន់មួយចំនួន ហើយ ប្រជាជនសៀរ៉ាឡេអូនជាច្រើន នឹងជំទាស់ថាមនុស្សដែលត្រូវបានកាត់សេចក្តីរួច គ្រាន់តែជាវិធានការយុត្តិធម៏ដែលមានចរិតលក្ខណ:ជានិមិត្តរូបតែប៉ុណ្ណោះ ជាពិសេសប្រសិនបើនីត្យានុកូលភាពរបស់តុលាការនេះនៅតែមានកម្រិត ។ ប្រព័ន្ធនៃការចូលរួមវិភាគផ្នែកថវិកាដោយស្មគ្រចិត្ត តែងតែបានដាក់ឲ្យតុលាការពិសេសនូវស្ថានភាពលំបាក ជាពិសេសបង្កជាឧបសគ្គក្នុងការធ្វើផែនការ ។ ម្យ៉ាងវិញទៀត សេរីភាពរួចផុតពីការត្រួតត្រារបស់អង្គការសហប្រជាជាតិ ផ្តល់ឲ្យតុលាការពិសេសនូវភាពបត់បែនក្នុងការជ្រើសរើសបុគ្គលិក ។
- *កេរ្តិ៍មរតក:* កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតកេរ្តិ៍កេត ត្រូវរារាំងដោយសារការទំនាក់ទំនងមិនសូវល្អជាមួយអ្នកប្រកបវិជ្ជាជីវ:ច្បាប់ក្នុងស្រុក និងដោយសារតែចរិតឯករាជ្យម្ចាស់ការរបស់តុលាការ ។ ប៉ុន្តែនឹងមានសារ:ប្រយោជន៏ដោយប្រយោលដោយសារការបញ្ចូលកេរមរតទៅក្នុងរចនាសម្ព័ន្ធរបស់តុលាការ ហើយ កេរ្តិ៍កេតដែលមានភាពវត្តមានផ្សេងទៀតកំពុងតែដំណើរការ ។

វាហាក់ដូចជាប្រញាប់ពេកក្នុងប្រកាសពីការចូលរួមចំណែករបស់តុលាការពិសេស ប៉ុន្តែតុលាការបានបង្កើតនូវមេរៀនដ៏មានតម្លៃជាច្រើនសម្រាប់ថ្ងៃអនាគត ។ បញ្ហាជាក់លាក់ទាក់ទងទៅនឹងការអនុវត្តគំរូ ត្រូវតែបានកែលំអនៅថ្ងៃអនាគត ។